**ស្ថានទូតអូស្ត្រាលី**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤

## អបអរខួបទី៥០ឆ្នាំនៃកម្មវិធីកិច្ចសហប្រតិបត្តិការអង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលី

ឆ្នាំនេះជាខួបទី៥០ឆ្នាំនៃកម្មវិធីកិច្ចសហប្រតិបត្តិការអង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលី(ANCP) ដែលជាកម្មវិធីជំនួយមួយក្នុងចំណោមកម្មវិធីជំនួយដែលមានរយៈពេលយូរបំផុតរបស់ប្រទេសអូស្ត្រាលី។

ANCP គាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលីដែលទទួលស្គាល់នៅអូស្ត្រាលី និងបណ្តាអង្គការដៃគូក្នុងស្រុករបស់ពួកគេ ដើម្បីអនុវត្តគម្រោងក្នុងសហគមន៍ ដែលផ្តល់ផលជាវិជ្ជមានផ្ទាល់ និងច្បាស់លាស់។

ចាប់តាំងពីការចាប់ផ្តើមដំបូងក្នុងឆ្នាំ ១៩៧៤ មកដល់បច្ចុប្បន្ន ANCP ផ្តល់មូលនិធិដល់អង្គការមិនមែនរដ្ឋាភិបាលប្រមាណ៦០ ដើម្បីអនុវត្តគម្រោងជាង៨០០ នៅក្នុងប្រទេសចំនួន៥០ ដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនជិត ៥លាននាក់។

នៅកម្ពុជា ឆ្នាំនេះ ANCP កំពុងផ្តល់ជំនួយជាថវិកាចំនួន ៧,៧ លានដុល្លារអូស្ត្រាលី ដើម្បីគាំទ្រ ២៦អង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលី និងបណ្តាអង្គការដៃគូក្នុងស្រុករបស់ពួកគេ ដើម្បីអនុវត្តគម្រោងចំនួន ៤៧ នៅទូទាំងប្រទេសកម្ពុជា។

អង្គការដៃគូដែលទទួលបានជំនួយនៅក្នុងឆ្នាំនេះ មានដូចជា៖

- អង្គការអាហ្វីដា (APHEDA) ដើម្បីកាត់បន្ថយជំងឺដែលទាក់ទងនឹងសារធាតុអាបេស្តុស និងធ្វើអោយប្រសើរឡើងនូវលក្ខខណ្ឌការងារសម្រាប់ស្ត្រី
- អង្គការការីតាស (Caritas) ដើម្បីធ្វើអោយប្រសើរឡើងនូវការអនុវត្តកសិកម្មដែលធន់នឹងអាកាសធាតុ នៅក្នុងខេត្តរតនគិរី និងស្ទឹងត្រែង
- អង្គការមូលនិធិកុមារកម្ពុជា (ChildFund) ដើម្បីធ្វើអោយប្រសើរឡើងនូវលទ្ធផលសិក្សារបស់កុមារដែលមានពិការភាព នៅតាមជនបទក្នុងខេត្តបាត់ដំបង
- អង្គការ សហជីពឥណទានមូលនិធិអូស្ត្រាលី (Credit Union Foundation Australia) ដើម្បីបង្កើនសមត្ថភាពសហគ្រិនអាជីវកម្មខ្នាតតូច

- មូលនិធិហ្រ្វេដហូឡូ (Fred Hollows Foundation) ដើម្បីផ្តល់ការវះកាត់ និងព្យាបាលជំងឺភ្នែកឡើងបាយ សម្រាប់អ្នកមិនមានលទ្ធភាពបង់ថ្លៃសេវា
- អង្គការម៉ារីស្តូប (Marie Stopes) ដើម្បីបង្កើនភាពងាយស្រួល និងគុណភាព របស់សេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ
- អង្គការ SeeBeyondBorders ដើម្បីលើកកម្ពស់គុណភាពការបង្រៀន និងការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់បង្រៀន ក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប
- អង្គការ WaterAid ដើម្បីធ្វើអោយប្រសើរឡើងនូវសេវាទឹកស្អាត និងអនាម័យ តាមមន្ទីរពេទ្យ ក្នុងខេត្តកំពង់ឆ្នាំង

អង្គការដៃគូរបស់យើងក៏ធ្វើការរៃអង្គាសថវិកាពីសហគមន៍អូស្រ្តាលី និងជំរុញការគាំទ្រពីសាធារណជន និងការរួមចំណែកស្ម័គ្រចិត្ត សម្រាប់គម្រោងរបស់ពួកគេផងដែរ។

ឯកអគ្គរដ្ឋទូត ដេរិក យីប បានមានប្រសាសន៍ថា "ការវាយតម្លៃដោយឯករាជ្យតែងតែរកឃើញថា ANCP ផ្តល់ផលជាវិជ្ជមាន និងបានលទ្ធផលលើសពីការផ្តល់មូលនិធិប្រចាំឆ្នាំទៅទៀត ហើយយើងមានទំនាក់ទំនងយូរអង្វែងជាមួយអង្គការក្នុងស្រុក និងសហគមន៍នៅទីនេះផងដែរ"។

"យើងសូមកោតសរសើរយ៉ាងខ្លាំងចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាលអូស្រ្តាលីរបស់យើង និងបណ្តាដៃគូអភិវឌ្ឍន៍ក្នុងស្រុក។ សង្គមស៊ីវិលដ៏រឹងមាំដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយបំពេញ និងគាំទ្រការងាររបស់រាជរដ្ឋាភិបាល ជាពិសេសនៅតំបន់ដាច់ស្រយាល និងជាមួយសហគមន៍ដែលងាយរងគ្រោះ។

ព័ត៌មានបន្ថែមអំពី ANCP៖ https://www.dfat.gov.au/development/who-we-work-with/ngos/ancp/australian-ngo-cooperation-program

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au